**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុន ហប ឡុក (ខេមបូឌា) ឯ.ក
## ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង០៨ និង០០នាទី ព្រឹក នៅក្នុងរោងចក្រ **ហប ឡុក (ខេមបូឌា) ឯ.ក** មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន នឹងតំណាងកម្មករ និយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាព បច្ចុប្បន្ននៃក្រុមហ៊ុនដែលគ្មានការបញ្ជាទិញដែលបណ្តាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ២៣៦នាក់(ស្រី១៦៥នាក់) រយៈពេល ៩ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៤ ។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករ និយោជិត បានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ១៥ដុល្លាសហរដ្ឋអាមេរិចក្នុងរយៈពេល ៩ថ្ងៃ ៕

ក្រុមហ៊ុនឯកភាពបើកប្រាក់ឧបត្ថម្ភជូននៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៤។

អង្គប្រជុំបានចប់នៅវេលាម៉ោង០៨ និង ៣០នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីក រាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោយល់សហការគ្នាយ៉ាងរលូន ។

ថ្ងៃអង្គារ ១៥ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
កណ្តាល ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤

**តំណាងក្រុមហ៊ុន**

**ស្នាមមេដៃតំណាងកម្មករ និយោជិត**